**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

លេខ ០២៤ ស.អ.យ.

*រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១០*

# សារាចរណែនាំ

## ស្តីពី

## ការកែប្រែតម្លៃឯកតា នៃសន្ទស្សន៍បៀវត្សរ៍មូលដ្ឋាន និង ការបង្កើនបៀវត្សរ៍សុទ្ធសាធរបស់មន្ត្រីរាជការ

កន្លងមករាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ឈ្លាសវៃរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានតម្លើងតម្លៃឯកតា នៃសន្ទស្សន៍បៀវត្សរ៍មូលដ្ឋានសម្រាប់មន្ត្រីរាជការស៊ីវិល និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងបង្កើនបៀវត្សរ៍សុទ្ធសាធសម្រាប់និវត្តជន ជនបាត់បង់សមត្ថភាពការងារ ជនបាត់បង់សមត្ថភាពពលកម្ម និងជនពិការ ដែលជាអតីតយុទ្ធជនជាបន្តបន្ទាប់ ដើម្បីលើកកម្ពស់ជីវភាពរស់នៅ ។ ដោយអនុវត្តតាមស្មារតី នៃអនុក្រឹត្យលេខ ១៦៧ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១០ ស្តីពីការកែប្រែតម្លៃឯកតា នៃសន្ទស្សន៍បៀវត្សរ៍មូលដ្ឋាន និងការបង្កើនបៀវត្សរ៍សុទ្ធសាធរបស់មន្ត្រីរាជការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សូមធ្វើការណែនាំដល់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និងបេឡាជាតិអតីតយុទ្ធជន ដូចតទៅ ៖

### ១. និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងមន្ត្រីរាជការស៊ីវិល

ក - ការគណនាប្រាក់សោធនរបស់និវត្តជន ត្រូវអនុវត្តតាមរូបមន្តដូចខាងក្រោម ៖

| | | |
|---|---|---|
| ប្រាក់សោធនសរុបប្រចាំខែថ្មី | = | **ប្រាក់សោធនសុទ្ធសាធ** + ប្រាក់តម្លើងឱ្យស្មើបៀវត្សរ៍មូលដ្ឋានអប្បបរមា + ប្រាក់បង្គ្រប់ + ប្រាក់បន្ថែមឱ្យស្មើប្រាក់សោធនចាស់ + ប្រាក់វិភាជន៍គ្រួសារ + ប្រាក់ហានិភ័យ + ប្រាក់ឧបត្ថម្ភផ្សេងទៀត ប្រសិនបើមាន |
| **ប្រាក់សោធនសុទ្ធសាធ** | = | សន្ទស្សន៍បៀវត្សរ៍មូលដ្ឋាន × ១០៥០ រៀល × អត្រាភាគរយប្រាក់សោធន |

ខ - ការគណនាប្រាក់សោធនរបស់ជនបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវអនុវត្តតាមរូបមន្តដូចខាងក្រោម ៖

| | | |
|---|---|---|
| ប្រាក់សោធនសរុបប្រចាំខែថ្មី | = | **ប្រាក់សោធនសុទ្ធសាធ** + ប្រាក់តម្លើងឱ្យស្មើ៩០%នៃបៀវត្សរ៍មូលដ្ឋានអប្បបរមា + ប្រាក់បង្គ្រប់ + ប្រាក់បន្ថែមឱ្យស្មើប្រាក់សោធនចាស់ + ប្រាក់វិភាជន៍គ្រួសារ + ប្រាក់ហានិភ័យ + ប្រាក់ឧបត្ថម្ភផ្សេងទៀត ប្រសិនបើមាន |
| **ប្រាក់សោធនសុទ្ធសាធ** | = | សន្ទស្សន៍បៀវត្សរ៍មូលដ្ឋាន × ១០៥០ រៀល × អត្រាភាគរយប្រាក់សោធន |

គ - ត្រូវរៀបចំសំណុំលិខិតស្នើសុំប្រាក់សោធនថ្មី ដូចខាងក្រោម ៖

- លិខិតស្នើសុំតម្លើងប្រាក់សោធនជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ០១ ច្បាប់
- តារាងបើកប្រាក់សោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈប្រចាំខែចុងក្រោយ ០១ ច្បាប់
- តារាងបើកប្រាក់សោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈប្រចាំខែថ្មី ០៣ ច្បាប់

បន្ទាប់ពីមានការឯកភាពរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា លើតារាងប្រាក់សោធន



ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារ : (៨៥៥) ២៣ ៧២៦០៨៦
Ministry of Social Affairs, Veterans and Youth Rehabilitation, #788, Monivong Blvd., Phnom Penh, Cambodia. Fax/Phone: (855) 23 726 086

មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត មានសិទ្ធិចុះហត្ថលេខានៅលើទំព័រដែលចែងពីកាលបរិច្ឆេទប្តូរប្រាក់សោធន នៃសៀវភៅនិវត្តជន និងសៀវភៅជនបាត់បង់សម្បទាវិជ្ជាជីវៈ។

**ឃ** - ចំពោះមន្ត្រីរាជការស៊ីវិលដែលត្រូវបានដាក់ឱ្យចូលនិវត្តន៍ ឬចូលបាត់បង់សម្បទាវិជ្ជាជីវៈ ដោយក្រសួង ស្ថាប័នសាមី ត្រូវគណនាប្រាក់សោធនតាមរូបមន្តដូចខាងលើនេះផងដែរ។

## ២ - និវត្តជន ជនបាត់បង់សមត្ថភាពការងារ និងជនពិការដែលជាអតីតយុទ្ធជន

**ក** - ការគណនាប្រាក់បង្កើន ២០% (ម្ភៃភាគរយ) នៃបៀវត្សរ៍ឋានន្តរស័ក្តិ ឬបៀវត្សរ៍សុទ្ធសាធរបស់និវត្តជន ជនបាត់បង់សមត្ថភាពការងារ និងជនពិការដែលជាអតីតយុទ្ធជន ត្រូវអនុវត្តតាមរូបមន្តដូចខាងក្រោម ៖

- រូបមន្តនៃការគណនាប្រាក់បង្កើនរបស់និវត្តជន ជនបាត់បង់សមត្ថភាពការងារ និងជនពិការ ៖

$$\text{ប្រាក់បង្កើន ២០\%} = \frac{\text{២០ × បៀវត្សរ៍ឋានន្តរស័ក្តិ ឬបៀវត្សរ៍មូលដ្ឋាន}}{\text{១០០}}$$

- រូបមន្តនៃការគណនាប្រាក់បង្កើនរបស់ជនពិការដែលជាអតីតមន្ត្រីរាជការស៊ីវិល ៖

$$\text{ប្រាក់បង្កើន ២០\%} = \frac{\text{២០ × បៀវត្សរ៍សុទ្ធសាធ ឬបៀវត្សរ៍មូលដ្ឋាន}}{\text{១០០}}$$

- រូបមន្តនៃការគណនាប្រាក់បង្កើនរបស់ជនពិការដែលជាអតីតមន្ត្រី ភូមិ ឃុំ កងសេនាជន និងប្រជាជន ៖

$$\text{ប្រាក់បង្កើន ២០\%} = \frac{\text{២០ × បៀវត្សរ៍ឋានន្តរស័ក្តិ ឬបៀវត្សរ៍មូលដ្ឋានអប្បបរមា}}{\text{១០០}}$$

**ខ** - គ្រប់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត មានភារកិច្ចរៀបចំប្រាក់បង្កើននេះ និងបំពេញបែបបទស្នើសុំទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**គ** - បញ្ជីរាយនាមអតីតយុទ្ធជនគ្រប់ប្រភេទដែលបានបង្កើនប្រាក់ ២០ ភាគរយ ត្រូវផ្ញើជូនបេឡាជាតិអតីតយុទ្ធជន ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់ការអនុវត្តន៍ និងបូកសរុបរបាយការណ៍ជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

តម្លៃឯកតា នៃសន្ទស្សន៍បៀវត្សរ៍មូលដ្ឋាន និងការបង្កើនបៀវត្សរ៍សុទ្ធសាធ ត្រូវអនុវត្តចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១១ តទៅ។

គ្រប់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និងបេឡាជាតិអតីតយុទ្ធជន ត្រូវអនុវត្តតាមស្មារតី នៃខ្លឹមសារសារាចរណែនាំនេះ ឱ្យមានប្រសិទ្ធភាព ។/.

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- អាជ្ញាធរសវនកម្មជាតិ
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
  "ដើម្បីជូនជ្រាប"
- គ្រប់អង្គភាពក្រោមឱវាទក្រសួង ស.អ.យ
  "ដើម្បីអនុវត្ត"
- ឯកសារ - កាលប្បវត្តិ

## តារាងបៀវត្សរ៍មូលដ្ឋាន

| ក្រុម ខណ្ឌ | ឋានន្តរសក្តិ | ថ្នាក់ ១៤ | ១៣ | ១២ | ១១ | ១០ | ៩ | ៨ | ៧ | ៦ | ៥ | ៤ | ៣ | ២ | ១ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ក១ | ឧត្តមមន្ត្រី | | | | | | | | | ៤៣៦ | ៤៥៧ | ៤៨២ | ៥០៦ | ៥២៨ | ៥៥០ |
| ក២ | វរៈមន្ត្រី | | | | | ៣៦១ | ៣៧៣ | ៣៨៧ | ៤០២ | ៤១៩ | ៤៣៧ | ៤៥៤ | ៤៦៧ | ៤៧៨ | ៤៨៧ |
| ក៣ | អនុមន្ត្រី | ៣១៥ | ៣២៣ | ៣៣១ | ៣៤០ | ៣៤៩ | ៣៥៩ | ៣៦៩ | ៣៨០ | ៣៩០ | ៣៩៩ | ៤០៧ | ៤១៤ | ៤២០ | ៤២៥ |
| ខ១ | នាយក្រមការ | | | | | | | | | ៣០៨ | ៣២៤ | ៣៤៤ | ៣៦០ | ៣៧៤ | ៣៨៥ |
| ខ២ | ក្រមការដើមខ្សែ | | | | | ២៥២ | ២៦២ | ២៧២ | ២៨៣ | ២៩៥ | ៣០៦ | ៣១៦ | ៣២៥ | ៣៣៣ | ៣៤០ |
| ខ៣ | ក្រមការ | ២២០ | ២២៥ | ២៣០ | ២៣៦ | ២៤៣ | ២៥១ | ២៥៩ | ២៦៦ | ២៧៣ | ២៧៩ | ២៨៤ | ២៨៩ | ២៩៣ | ២៩៧ |
| គ១ | នាយលេខាធិការ | | | | | | | | | ២១២ | ២២៣ | ២៣៥ | ២៤៥ | ២៥៤ | ២៦២ |
| គ២ | លេខាធិការដើមខ្សែ | | | | | ១៧៣ | ១៧៨ | ១៨៥ | ១៩៣ | ២០១ | ២០៨ | ២១៥ | ២២២ | ២២៨ | ២៣៣ |
| គ៣ | លេខាធិការ | ១៥០ | ១៥៤ | ១៥៨ | ១៦៣ | ១៦៨ | ១៧៤ | ១៧៩ | ១៨៤ | ១៨៨ | ១៩២ | ១៩៥ | ១៩៨ | ២០០ | ២០២ |
| ឃ១ | នាយភ្នាក់ងាររដ្ឋបាល | | | | | | | | | ១៤១ | ១៤៩ | ១៥៧ | ១៦៤ | ១៧០ | ១៧៥ |
| ឃ២ | ភ្នាក់ងាររដ្ឋបាលដើមខ្សែ | | | | | ១១៣ | ១១៧ | ១២២ | ១២៨ | ១៣៤ | ១៣៩ | ១៤៤ | ១៤៨ | ១៥២ | ១៥៥ |
| ឃ៣ | ភ្នាក់ងាររដ្ឋបាល | ១០០ | ១០២ | ១០៤ | ១០៦ | ១០៩ | ១១២ | ១១៦ | ១២០ | ១២៣ | ១២៦ | ១២៩ | ១៣១ | ១៣៣ | ១៣៥ |

## តារាងបៀវត្សរ៍មូលដ្ឋានគុណនឹងសន្ទស្សន៍ ១០៥០ សម្រាប់ឆ្នាំ ២០១១

| ក្រុម ខណ្ឌ | ឋានន្តរសក្តិ | ថ្នាក់ 14 | 13 | 12 | 11 | 10 | 9 | 8 | 7 | 6 | 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ក១ | ឧត្តមមន្ត្រី | | | | | | | | | 457,800 | 479,850 | 506,100 | 531,300 | 554,400 | 577,500 |
| ក២ | វរៈមន្ត្រី | | | | | 379,050 | 391,650 | 406,350 | 422,100 | 439,950 | 458,850 | 476,700 | 490,350 | 501,900 | 511,350 |
| ក៣ | អនុមន្ត្រី | 330,750 | 339,150 | 347,550 | 357,000 | 366,450 | 376,950 | 387,450 | 399,000 | 409,500 | 418,950 | 427,350 | 434,700 | 441,000 | 446,250 |
| ខ១ | នាយក្រមការ | | | | | | | | | 323,400 | 340,200 | 361,200 | 378,000 | 392,700 | 404,250 |
| ខ២ | ក្រមការដើមខ្សែ | | | | | 264,600 | 275,100 | 285,600 | 297,150 | 309,750 | 321,300 | 331,800 | 341,250 | 349,650 | 357,000 |
| ខ៣ | ក្រមការ | 231,000 | 236,250 | 241,500 | 247,800 | 255,150 | 263,550 | 271,950 | 279,300 | 286,650 | 292,950 | 298,200 | 303,450 | 307,650 | 311,850 |
| គ១ | នាយលេខាធិការ | | | | | | | | | 222,600 | 234,150 | 246,750 | 257,250 | 266,700 | 275,100 |
| គ២ | លេខាធិការដើមខ្សែ | | | | | 181,650 | 186,900 | 194,250 | 202,650 | 211,050 | 218,400 | 225,750 | 233,100 | 239,400 | 244,650 |
| គ៣ | លេខាធិការ | 157,500 | 161,700 | 165,900 | 171,150 | 176,400 | 182,700 | 187,950 | 193,200 | 197,400 | 201,600 | 204,750 | 207,900 | 210,000 | 212,100 |
| ឃ១ | នាយភ្នាក់ងាររដ្ឋបាល | | | | | | | | | 148,050 | 156,450 | 164,850 | 172,200 | 178,500 | 183,750 |
| ឃ២ | ភ្នាក់ងាររដ្ឋបាលដើមខ្សែ | | | | | 118,650 | 122,850 | 128,100 | 134,400 | 140,700 | 145,950 | 151,200 | 155,400 | 159,600 | 162,750 |
| ឃ៣ | ភ្នាក់ងាររដ្ឋបាល | 105,000 | 107,100 | 109,200 | 111,300 | 114,450 | 117,600 | 121,800 | 126,000 | 129,150 | 132,300 | 135,450 | 137,550 | 139,650 | 141,750 |